## ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
## អភិបូជាអធិដ្ឋានពេញមួយយប់សម្រាប់ការត្រាស់ហៅ
## កាម៉ែល ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៩
## យើងធ្វើដំណើររហូតឃើញព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ

**អត្ថបទទី១៖ ទុតិយកថា ៣០,១៥-២០**

ថ្ងៃនេះ ខ្ញុំឲ្យអ្នកជ្រើសរើសយកជីវិត ឬសេចក្តីស្លាប់ អំពើល្អ ឬអំពើអាក្រក់។ ទក ៣០,១៥

**ដំណឹងល្អ៖ លូកា ៩,២២-២៥**

ព្រះយេស៊ូមានព្រះបន្ទូលទៅគេទាំងអស់គ្នាថា៖ "បើអ្នកណាចង់មកតាមក្រោយខ្ញុំ ត្រូវលះបង់ខ្លួនឯងចោល ត្រូវលីឈើឆ្កាងរបស់ខ្លួនរៀងរាល់ថ្ងៃ ហើយមកតាមខ្ញុំចុះ"។ លក ៩,២៣

បងប្អូនជាទីស្រឡាញ់!

កន្លែងស្ងាត់នៅខាងក្រៅអត់សូវមានទេ ប៉ុន្តែសំខាន់ទៅរកកន្លែងស្ងាត់នៅខាងក្នុងចិត្ត នៅក្នុងរដូវ៤០ថ្ងៃធ្វើដូចម្តេចចូលទៅក្នុងដួងចិត្តរបស់យើង ដើម្បីទៅរកភាពស្ងៀមស្ងាត។ អត្ថបទទី១ បានណែនាំឲ្យយើងចូលយ៉ាងជ្រៅនៅក្នុងជីវិតរបស់យើងជាគ្រីស្តបរិស័ទ "**ខ្ញុំឲ្យអ្នកជ្រើសរើសយកជីវិតឬសេចក្តីស្លាប់? អំពើល្អឬអំពើអាក្រក់? ត្បិតខ្ញុំបង្គាប់អ្នកនៅថ្ងៃនេះឲ្យស្រឡាញ់ព្រះជាម្ចាស់ ជាព្រះរបស់អ្នកហើយដើរតាមមាគារបស់ព្រះអង្គ**"។ ថ្ងៃនេះយើងត្រូវការជ្រើសរើស រវាងជីវិតនឹងសេចក្តីស្លាប់ អំពើអាក្រក់និងអំពើល្អ ប្រហែលយើងចង់ឆ្លើយភ្លាមយើងរើសជីវិតនិងអំពើល្អ។ យើងឆ្លើយតាមបបូរម៉ាត់ស្រួលណាស់ ប៉ុន្តែបើយើងពិចារណាជីវិតរបស់យើង យើងឃើញច្រើនដងយើងវង្វេងផ្លូវ ប៉ុន្មានដងយើងធ្វើអំពើបាប។ ទោះបីយើងប្រកាសឱព្រះជាម្ចាស់អើយ! ខ្ញុំចង់ជ្រើសរើសជីវិត ខ្ញុំចង់ជ្រើសរើសអំពើល្អ ប៉ុន្តែជីវិតរបស់យើងអត់ទាន់ភ្ជាប់ទៅនឹងអំពើល្អរបស់ព្រះជាម្ចាស់បានទេ។

ដូច្នេះរដូវ៤០ថ្ងៃជារដូវពិសេស ដើម្បីចូលយ៉ាងជ្រៅនៅក្នុងភាពសម្ងាត់នៃដួងចិត្តរបស់យើង និងដើម្បីពិចារណាម្តងទៀតជីវិតរបស់ខ្ញុំទៅណា? ជីវិតរបស់ខ្ញុំដើម្បីអ្វី? ផ្លែនៃជីវិតរបស់ខ្ញុំមានអ្វីខ្លះ? ពិតមែនយើងជ្រើសរើសជីវិត ពិតមែនយើងចង់ជ្រើសរើសអំពើល្អ "**ត្បិតខ្ញុំអ្នកបង្គាប់អ្នកនៅថ្ងៃនេះ ឲ្យស្រឡាញ់ព្រះអម្ចាស់ជាព្រះរបស់អ្នកហើយដើរតាមមាគារបស់ព្រះអង្គ**" ដើម្បីរើសអំពើល្អ ដើម្បីរើសជីវិតយើងត្រូវតែស្តាប់បង្គាប់និងស្រឡាញ់ព្រះជាម្ចាស់ និងយកចិត្តទុកដាក់ដើម្បីដើរតាមមាគារបស់ព្រះជាម្ចាស់។ សន្តតេរេសា នៅក្នុងជីវិតរបស់គាត់បានរើសអំពើល្អ ជាពិសេសបានរកឃើញផ្លូវមួយយ៉ាងច្បាស់លាស់ ដើម្បីទៅដល់ព្រះជាម្ចាស់គឺភ្ជាប់ជាមួយព្រះយេស៊ូតែម្តង។ ថ្ងៃនេះ ព្រះជាម្ចាស់រំឭកយើងម្តងទៀតឲ្យយើងស្រឡាញ់ព្រះជាម្ចាស់អស់ពី

ដួងចិត្តអស់ពីជំនឿអស់ពីស្មារតី ដើម្បីធ្វើដំណើរជាមួយព្រះជាម្ចាស់ពីមួយថ្ងៃទៅមួយថ្ងៃ។ យើងមាន៤០ថ្ងៃ ដើម្បីធ្វើដំណើរប៉ុន្តែមិនមែនតែធ្វើដំណើរពីភូមិមួយទៅភូមិមួយ ពីព្រះវិហារមួយទៅព្រះវិហារមួយ ពីកន្លែងមួយទៅកន្លែងមួយទៀត តែជាដំណើរនៅខាងក្នុងដួងចិត្តរបស់យើង។ ជីវិតរបស់យើងមិនមែនជីវិតស្ងៀមស្ងាត់ មិនមែនជីវិតណែនាំឲ្យយើងងងុយដេក ជីវិតរបស់យើងជាមួយព្រះជាម្ចាស់ ណែនាំឲ្យយើងធ្វើដំណើរនៅក្នុងដួងចិត្តរបស់យើង។

ថ្ងៃនេះ ដែលយើងអធិដ្ឋានសម្រាប់ការត្រាស់ហៅ យើងបានស្តាប់គម្ពីរដែលសំខាន់បំផុតនៅពេលយើងជ្រើសរើសព្រះជាម្ចាស់ នៅពេលយើងជ្រើសរើសព្រះយេស៊ូដើម្បីដំណើរជាមួយ។ ក្នុងអត្ថបទគម្ពីរដំណឹងល្អ "**បុត្រមនុស្សត្រូវរងទុក្ខវេទនាយ៉ាងខ្លាំង។ ពួកព្រឹទ្ធាចារ្យ ពួកនាយកបូជាចារ្យ ពួកបណ្ឌិតខាងវិន័យ នឹងបោះបង់លោកចោល ថែមទាំងសម្លាប់លោកទៀតផង**"។ ពេលដែលយើងដើរតាមព្រះជាម្ចាស់យើងមិនដើរតាមផ្លូវយ៉ាងស្រួលទេ ប៉ុន្តែត្រូវការឆ្លងកាត់តាមការរង់ទុក្ខលំបាក ឆ្លងការបោះបង់ចោល ដោយសង្គមមើលងាយយើងឬណែនាំឲ្យយើងទៅតាមផ្លូវផ្សេង ដូច្នេះយើងត្រូវប្រឆាំងនឹងគេរហូតដល់ស្លាប់នៅក្នុងអ្វីដែលសំខាន់ក្នុងដួងចិត្តរបស់យើង។ ប្រហែលយើងជ្រើសរើសព្រះជាម្ចាស់ ប្រសិនបើអត់មានការសម្លាប់នៅក្នុងខ្លួនរបស់យើង យើងទៅអត់បានទេ ប៉ុន្តែបីថ្ងៃក្រោយមកលោកនឹងរស់ឡើងវិញ។ យើងឆ្លងកាត់ទុក្ខលំបាក យើងឆ្លងកាត់សេចក្តីស្លាប់ យើងឆ្លងកាត់ការមើលងាយពីគេ ក៏ប៉ុន្តែយើងដឹងថានេះមិនមែនជាបញ្ចប់នៃជីវិតរបស់យើង ដោយសារព្រះជាម្ចាស់ណែនាំងឲ្យយើងជ្រើសរើសជីវិតដើម្បីរកឃើញសុភមង្គល។ សុភមង្គលនេះយើងជឿថាមាន ដោសារព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ។

៤០ថ្ងៃដែលយើងមាន ជាពេលវេលាដើម្បីចូលនៅក្នុងដួងចិត្តនិងធ្វើដំណើររហូតដល់យើងឃើញព្រះយេស៊ូមានព្រះជន្មនរស់ឡើងវិញ។ ដើម្បីរងទុក្ខលំបាក ដើម្បីសម្លាប់អ្វីៗទាំងអស់ដែលអត់ល្អនៅក្នុងដួងចិត្តរបស់យើង មធ្យោបាយដែលព្រះយេស៊ូឲ្យគឺលះបង់ខ្លួនឯងចោលនិងលីឈើឆ្កាង រដូវ៤០ថ្ងៃណែនាំឲ្យយើងធ្វើផ្ទុយនឹងអ្វីដែលយើងឃើញនៅក្នុងសង្គម។ ក្នុងអភិបូជាបុណ្យរោយផេះ សម្តេចប៉ាបបាននិយាយខ្លាំងដល់យើងជាគ្រីស្តបរិស័ទ ដល់ពិភពលោកដែរគឺ ឲ្យយើងជ្រើសរើសជីវិត ប៉ុន្តែជ្រើសរើសជីវិតមានន័យថាលះបង់ចោលទ្រព្យសម្បត្តិ លះបង់ចោលការល្បួងនៅក្នុងលោកិយ លះបង់ចោលវប្បធមិសុខភាពដែលគិតថាសំខាន់ លះបង់ចោលអ្វីដែលសព្វថ្ងៃសង្គមរបស់យើងបង្ហាញថានេះជាសំខាន់ (បានទទួលច្រើន បានទ្រព្យសម្បត្តិ បានសម្ភារនិយម បានអត្មានិយម លះបង់ចោលអ្វីៗទាំងអស់) ដោយសារនេះណែនាំឲ្យភ្នែករបស់យើងមើលច្រឡំ។ ផ្ទុយទៅវិញយើងដឹងថា ទ្រព្យសម្បត្តិ និងអ្វីៗដែលលោកិយចង់ប្រគល់ឲ្យយើង ការល្បួងដែលយើងឃើញពីមួយថ្ងៃទៅមួយថ្ងៃ បីដូចជារោយផេះដែលណែនាំឲ្យ

មានអត្ថន័យតែមួយភ្លែតៗ។ ផ្ទុយទៅវិញព្រះជាម្ចាស់ ណែនាំឲ្យយើងរកឃើញភ្លើងដែលស្ថិតស្ថេរជានិច្ច មានន័យថាឲ្យយើងរើសព្រះជាម្ចាស់។

ដើម្បីរើសព្រះជាម្ចាស់នៅក្នុងរដូវ៤០ថ្ងៃនេះ យើងត្រូវតែមើលព្រះឈើឆ្កាងដើម្បីចូលនៅក្នុងជីវិតរបស់ព្រះជាម្ចាស់។ លីឈើឆ្កាងមិនមែនពាក្យនិយាយតែប៉ុណ្ណឹង យើងចូលនៅក្នុងសក្ការៈបូជា ការលះបង់ចោលរបស់ព្រះយេស៊ូ។ ៤០ថ្ងៃខាងមុខ ឲ្យនឹកឃើញឈើឆ្កាងឲ្យជាប់នឹងភ្នែករបស់យើង ឲ្យជាប់នៅក្នុងដួងចិត្តរបស់យើង ដោយដឹងថាដើម្បីធ្វើដំណើររួមជាមួយព្រះយេស៊ូដើម្បីស្រឡាញ់ព្រះជាម្ចាស់ ដើម្បីចូលនៅក្នុងផ្លូវនៃដំណើរជីវិតរបស់ព្រះអង្គ។ ឲ្យយើងសម្លឹងមើលឈើឆ្កាងដោយដឹងថា នៅលើឈើឆ្កាងនេះពិតមែនមានព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ និងមានយើងដែរដើម្បីបន្តធ្វើដំណើររួមជាមួយព្រះអង្គនៅក្នុងជីវិតរបស់យើង និងធ្វើដំណើររហូតយើងឃើញព្រះយេស៊ូមានព្រះជន្មនរស់ឡើងវិញយ៉ាងពិតប្រាកដមែន។

ដូច្នេះថ្ងៃនេះ យើងអរព្រះគុណព្រះជាម្ចាស់ដែលបានត្រាស់ហៅយើងឲ្យយើងបានជួបជុំគ្នាដើម្បីអធិដ្ឋាន យើងនឹកឃើញដល់១៩៦នាក់ដែលនឹងទទួលអគ្គសញ្ញាជ្រមុជទឹក ក្នុងភូមិភាគភ្នំពេញនាបុណ្យចម្លងខាងមុខនេះ។ យើងអធិដ្ឋានអរព្រះគុណព្រះជាម្ចាស់ ដែលបានប្រទានបងស្រីសម្រាប់អធិដ្ឋាន២៤ម៉ោងលើ២៤ម៉ោង សម្រាប់ភូមិភាគយើង សម្រាបព្រះសហាគមន៍យើងជាពិសេសសម្រាប់ការត្រាស់ហៅ ប៉ុន្តែដោយដឹងថានេះជាតួនាទីយើងដែរ អធិដ្ឋានទូលអង្វរព្រះជាម្ចាស់ដើម្បីធ្វើដំណើរនៅក្នុងជីវិតរបស់យើង ជាពិសេសនៅក្នុងរដូវ៤០ថ្ងៃនេះ។ អាម៉ែន៕